មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ
លេខ ១៦ រប-៩៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គព្រះរាជអជ្ញាអមសាលាឧទ្ធរណ៍ ភ្នំពេញ**

**ជម្រាបមក**

**លោក ប្រធានតុលាការ រាជធានីភ្នំពេញ**

**សូមជ្រាប។**

**កម្មវត្ថុ:** ការអនុវត្តច្បាប់នីតិវិធីព្រហ្មទណ្ឌ ។

**យោង:** លិខិតបង្គាប់ការក្រសួងយុត្តិធម៌លេខ០៤.បរ.៩៤ ចុះថ្ងៃទី១៤ មីនា ១៩៩៤ ។

ខ្ញុំសូមជម្រាបរំលឹកលោកថា ច្បាប់នីតិវិធីព្រហ្មទណ្ឌដែលអនុម័តដោយរដ្ឋសភា នៃរដ្ឋកម្ពុជាកាលពីថ្ងៃទី២៩ មករា ១៩៩៣ មានអនុភាពអនុវត្តភ្លាមៗ ហើយថយក្រោយទៀត ។

ដូច្នេះសំណុំរឿងដែលបំពេញតាមទម្រង់នីតិវិធីឆ្នាំ១៩៨៦ ហើយពុំទាន់មានសេចក្តីសម្រេចពីតុលាការជាស្ថាពរពុំមានន័យត្រូវអនុវត្តបន្តទៅទៀតឡើយ ផ្ទុយទៅវិញត្រូវតែមានការសើរើអនុវត្តតាមបញ្ញត្តិមាត្រា ៦៧ កពពទ ដែលចែងថា រដ្ឋអជ្ញានិងអាចប្រើនីតិវិធីចោទប្រកាន់ផ្ទាល់ទៅតុលាការតែម្តង នោះបានតែក្នុងករណីដែលជនជាប់ចោទអាចនឹងត្រូវផ្តន្ទាទោសដាក់គុក ដែលអតិបរិមានៃទោសមិនលើសពី ១ឆ្នាំ បើពុំនោះទេ រដ្ឋអាជ្ញាត្រូវបញ្ជូនរឿងទៅចៅក្រមស៊ើបអង្កេតសិន និងបញ្ញត្តិមាត្រា ៦៨ កពពទ និងតទៅ ។

អាស្រ័យហេតុនេះ ខ្ញុំសូមលោកចាត់ការតម្រូវឲ្យមានការគោរពច្បាប់តាមន័យដូចបានជម្រាបខាងលើ ដើម្បីបានត្រឹមត្រូវជាប្រញាប់តទៅ ។

សូមកត់សម្គាល់ថា ដីកាចាប់ខ្លួនចេញដោយស្នងការនគរបាល ឬព្រះរាជអាជ្ញាគ្មានឥទ្ធិពលអនុវត្តឡើយ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៤

**អគ្គព្រះរាជអាជ្ញា**

**ហង់រ៉ូ រ៉ាកេន**

ចម្លងជូន
-ក្រសួងយុត្តិធម៌
-លោកស្រីជំនាញការ
-ព្រះរាជអាជ្ញាអមតុលាការរាជធានីភ្នំពេញ